# ១៨~រឿង អ្នកដំណើរពីរនាក់ដណ្ដើមគ្នាដេកកណ្ដាល

កាលពីដើមមនុស្សពីរនាក់ដើរទៅផ្លូវឆ្ងាយ ជួនយប់ក្នុងព្រៃងងឹតដើរទៅមិនរួច បបួលគ្នាដេកក្នុងព្រៃ ។ អ្នកទាំងពីរនាក់ចង់ដេកតែកណ្ដាល ប៉ុន្តែមិនដឹងធ្វើដូចម្ដេចនឹងបានដេកកណ្ដាល ។ បុរសទាំងពីរគិតគ្នាថា "បើដូច្នេះយើងដេកយកជើងទល់គ្នា" ហើយបុរសទាំងនោះក៏ដេកយកជើងទល់គ្នា លក់ទាំងពីរនាក់ទៅ ។ ក្រោយមកមានខ្លាឃើញមនុស្សដេកយកជើងទល់គ្នា ហើយទទូរសំពត់ជិតមើលមិនដឹងថាសត្វអ្វីវែងដូច្នេះ ឆ្ងល់ណាស់ ត្បិតមិនដែលឃើញក៏បបួលសត្វឯទៀតជាច្រើនមានទាំងដំរីក្របីគោ រមាសរមាំង ក្ដាន់ប្រើស ទ្រាយចចក ស្វានស្វាគ្រប់ប្រភេទអស់មកមើល គ្មានសត្វណាមួយស្គាល់សោះ ។ ក្រោយមកទៀតសត្វទាំងអស់គិតថា "ឥឡូវនេះនឹងមានអ្នកឯណាស្គាល់សត្វនេះច្រើនភាសាណាស់ហើយ នៅសល់សត្វអ្វីទៀត ដែលមិនទាន់បានមកមើល ?" សត្វទាំងនោះគិតគ្នាទៅឃើញនៅសល់តែទន្សាយពុំបានមក មួយទៀត ឮល្បីថាទន្សាយនោះ ជាអ្នកមានប្រាជ្ញាចេះនិយាយក្បួនច្បាប់ទំលាប់ ចេះកលមាយា ចាំទំនឹមទំនៀមច្រើនបើដូច្នេះយើងប្រើបងដំរីអោយទៅអញ្ជើញបងទន្សាយនោះទើបបាន ត្បិតបងទន្សាយបើមាននរណាទៅពឹងការអ្វីគាត់ប្រកាន់ខ្លួនណាស់ ។ សត្វទាំងនោះគិតគ្នាហើយ អោយដំរីទៅអញ្ជើញទន្សាយ ។ ដំរីទៅឃើញទន្សាយអង្គុយនៅលើក្បាលដំបូក ។ ទន្សាយឃើញដំរីយេកយោកមកពីនាយក៏សួរ "បងដំរីមានហេតុអ្វីបានជារលះរលាំងមក" ។ ដំរីឆ្លើយថា "បងទន្សាយ! ត្បិតមានសត្វអ្វីមួយចំឡែកណាស់ គ្មាននរណាស្គាល់សោះបានជាអស់សត្វក្នុងព្រៃនេះអោយខ្ញុំមកអញ្ជើញបងទន្សាយឯងទៅមើល ក្រែងបងទន្សាយឯងស្គាល់សត្វនោះ" ។ ឯទន្សាយឮដូច្នោះហើយឆ្លើយថា "សត្វនោះដូចម្ដេចតូចឬធំវែងឬខ្លី ?" ។ ដំរីថា "សត្វនោះធំចុងដើមតូចកណ្ដាល ហើយវែងប្រវែងប្រមាណប្រាំហត្ថ" ។ ទន្សាយឮដូច្នោះឆ្លើយឡើងថា "ឱបើដូច្នោះបងដំរីកុំព្រួយចិត្តចាំខ្ញុំទៅមើលអោយស្គាល់សត្វនោះ ប៉ុន្តែបងដំរីឯងអោយខ្ញុំជិះលើក្បាលបងឯងទៅ" ។ ដំរីឮដូច្នោះហើយដើរចូលទៅឱនក្បាលអោយទន្សាយជិះលើក្បាល ធ្វើជាក្អេងក្អាង លុះទៅដល់ហើយទន្សាយចុះពីក្បាលដំរីយកស្លឹកឈើដែលមានស្នាមដង្កូវវារដូចជាអក្សរកាន់លើកឡើងធ្វើជាសំបុត្រថា "អស់បងប្អូនស្ដាប់ខ្ញុំត្បិតខ្ញុំជាបំរើព្រះឥន្ទ្រៗលោកប្រើអោយនាំសំបុត្រមក" ហើយទន្សាយឡើងលើដំបូកធ្វើជាអានសំបុត្រថា "សត្វនេះព្រះឥន្ទ្រលោកប្រើមកឈ្មោះ សត្វយោគីយោគាយកទាំងអស់គ្នាយកទាំងអញយកទាំងឯង" ។ អស់សត្វឮទន្សាយមើលសំបុត្រថា "ព្រះឥន្ទ្រអោយមកយកទាំងអស់គ្នា" ក៏ស្ទុះបោលជាន់គ្នាស្លាប់ បាក់ដៃបាក់ជើងពាសពេញស្រែកលាន់ទាំងព្រៃ ។ មនុស្ស២នាក់នោះដឹងថាសត្វទាំងនោះផ្អើលភ្ញាក់រត់ជាន់គ្នាស្លាប់ដូច្នោះ ក្រោកឡើងលើកដៃសំពះទន្សាយថា "បងទន្សាយមានគុណនឹងយើងខ្លាំងណាស់ បើប្រសិនជាយើងមិនបានបងទន្សាយមកធ្វើឧបាយកលអោយយើងទេនោះសមខ្លាវានឹងខាំយើងស៊ីជាចំណីវាទៅហើយបងទន្សាយឯងមានប្រាជ្ញាល្មមធ្វើជាសុភាបាន" ។

ឯមនុស្សទាំងពីរនាក់ មើលទៅឃើញអស់សត្វជាន់គ្នាស្លាប់ពេញព្រៃដូច្នោះ បបួលគ្នាអារយកសាច់វែកទាំងពីរនាក់ ដើរបន្តិចឃើញខ្លាសំគមមួយ ដំរីវាជាន់បាក់ជើងដើរបានតិចៗក៏បបួលគ្នាយកខ្សែចងដឹកយកទៅលុះដើរទៅបន្តិចជួបនឹងអ្នកបររទេះគោ ។ ឯអ្នកបររទេះគោនោះឃើញអ្នកទាំងពីរវែកសាច់មកដូច្នោះ ក៏បញ្ឈប់រទេះសួរថា "អ្នកធ្វើដូចម្ដេចក៏បានសាច់ច្រើនម្ល៉េះ ?" ។ អ្នកនោះបញ្ឆោតថា "ឆ្កែកំបាក់ជើងខ្ញុំនេះឯងវាដេញខាំ ត្បិតឆ្កែនេះជាឆ្កែបណ្ដេញ ខ្ញុំតែងតែដេញសត្វមកមិនដែលស្ងួតស្ងាំងដល់មួយពេលទេ ក្រែងតែគ្មានសត្វ បើព្រៃណាមានសត្វហើយមិនដែលរួចនឹងអាឆ្កែបណ្ដេញខ្ញុំនេះទេ អោយឃើញតែស្នាមជើងនោះសង្ឃឹមបានឲ្យលាងផ្ទាំងអោយហើយទៅមុខជានឹងបានមិនដែលខានទេ" ។ ឯអ្នកបររទេះ ឮអ្នកនោះនិយាយអួតប្រាប់ដូច្នោះ ហេតុតែជាមនុស្សល្ងង់មិនស្គាល់ហើយចង់បានខ្លាកំបាក់ជើងសំគមនោះណាស់ គិតថាជាឆ្កែមែនទែនក៏និយាយអង្វរល្បួងលោមថា "បើដូច្នោះអ្នកអាណិតខ្ញុំៗសុំទិញឆ្កែអ្នកយកទៅបណ្ដេញត្បិតស្រុកខ្ញុំមានសត្វច្រើនណាស់" ។

អ្នករែកសាច់ឆ្លើយថា "បើខ្ញុំលក់ឆ្កែនេះអោយអ្នកឯងផ្ទះខ្ញុំសមនឹងក្រៀមផ្អាំង ហើយរកអ្វីគ្មានទេ ប៉ុន្តែអ្នកបានជួបនឹងខ្ញុំម្តងបើនិយាយគ្នាក៏មិនបានឆ្កែខ្ញុំនេះខ្ញុំស្រឡាញ់ វារកអ្វីប្រៀបគ្មានទេ បើអ្នកចង់ទិញតើអ្នកអោយថ្លៃប៉ុន្មាន?" ។ អ្នកបររទេះគោឆ្លើយថា "ខ្ញុំមានតែគោមួយនឹមនេះឯង ហើយគោនេះខ្ញុំស្រឡាញ់រកអ្វីប្រៀបគ្មានទេ តៀតបរមួយថ្ងៃទល់ល្ងាចមិនឈប់សោះក៏បានក្នុងមួយថ្ងៃអោយផឹកទឹកតែម្តងទាំងលឿនទៀត ក្នុងស្រុកអាយនេះ គ្មានគោណាលឿនស្មើទេតែឥឡូវនេះចិត្តខ្ញុំចង់បានឆ្កែអ្នកឯងយកទៅដេញសត្វឯស្រុកខ្ញុំៗសុំដូរជាថ្នូរគោមួយនឹមព្រមទាំងកណ្តឹងចង្ក្រងត្រដោកខ្សែទាមចន្ទោលគ្រប់ប្រដាប់ប្រដាស្រាប់តែឡើងជិះបរតែម្តង ខ្ញុំសុំតែខ្លួន និងប្រពន្ធចុះចេញ" ។

អ្នករែកសាច់ឮអ្នកបររទេះថា "ដូរជាគោមួយនឹមប្រដាប់ស្រាប់តែឡើងបរ" ក៏នឹកអរក្នុងចិត្តណាស់ ដោយសាររែកសាច់វាធ្ងន់ផងហើយធ្វើជាមិនចង់ដូរទេតែក្នុងចិត្តចង់ដូរណាស់និយាយថា "ឆ្កែខ្ញុំនេះខ្ញុំស្រឡាញ់ណាស់ ឥឡូវអ្នកមកសុំដូរពីខ្ញុំទៅខ្ញុំខំកាត់ចិត្តដូរអោយអ្នកទៅចុះ ប៉ុន្តែអ្នកថ្នមវាអោយល្អកុំអោយវាអត់ឃ្លានហើយអ្នកយកសាច់នេះទុកអោយវាស៊ីតាមផ្លូវទៅ" ។ ឯអ្នករែកសាច់អោយសាច់ទៅអ្នកនោះល្មមខ្លាស៊ីឆ្អែត ហើយយកសាច់ដាក់លើរទេះបរទៅ ។

អ្នកម្ចាស់រទេះគោនោះ ក៏ដឹកខ្លាសំគមកំបាក់ជើងទៅ ទៅបន្តិចទៅអោយសាច់ទៅខ្លាស៊ីតែរឿយៗ ។ ខ្លានោះបានសាច់ស៊ីមានកំលាំងក៏ក្រាញមិនចង់ទៅ ។ ត្រាតែដាច់ខ្សែ ហើយដើរចូលក្នុងព្រៃទៅ អ្នកនោះដឹងថាខ្លាបោលចូលទៅក្នុងព្រៃហើយក៏រត់ទៅចាប់ហើយហៅថា "បឺសៗអាក្លឹកមកឯអាយ" ។

ខ្លាឃើញមនុស្សទៅជិត បែរមកគំរាមធ្វើហ៊ែៗហ៊ៗ សន្ធាប់អោយអ្នកនោះអ្នកនោះឃើញខ្លាគំរាមគួរអោយខ្លាចដូច្នោះ ក៏ថយមកក្រោយវិញមិនហ៊ានតាម ទៅទៀត ប៉ុន្តែនឹកស្តាយមើលទៅរទេះទៅបាត់មិនដឹងជាទៅណា ។ អ្នកម្ចាស់ខ្លាបានរទេះគោនោះហើយក៏ម្ចីម្ចាដាក់អម្រែកលើរទេះឡើងជិះទាំងពីរនាក់បរជាប្រញាប់ទៅអោយផុតហួសពីមុខម្ចាស់រទេះនោះ ។ អ្នកម្ចាសរទេះដល់ខ្លាបោលចូលព្រៃទៅហើយនឹកស្តាយណាស់មិនដឹងគិតធ្វើដូចម្តេច ក៏បបួលប្រពន្ធត្រឡប់ទៅផ្ទះវិញ ។

## យកហោះទៅដូរហោះ